# ច្បាប់គោរពមាតាបិតា
# កិរិយាចិញ្ចឹមជីវិតដោយកម្រ
# ពុទ្ធប្រវត្តិ

បណ្ឌិត អ៊ូ-បុង

រៀបរៀង

អនុញ្ញាតនាយកក្រសួងឃោសនាការ

លេខ ២៣៣ ចុះថ្ងៃទី ៧ មីនា ១៩៥៥

បោះពុម្ពលើកទី ៣

រក្សាសិទ្ធិ

ព.ស. ២៤៩៨

គ.ស. ១៩៥៥

តម្លៃ ៨|០០

CA 45

# ច្បាប់គោរពមាតាបិតា
# កិរិយាចិញ្ចឹមជីវិតដោយការប្រ
# ពុទ្ធប្រវត្តិ

បណ្ឌិត អ៊ូ-ប៊ុង
រៀបរៀង

អនុញ្ញាតនាយកក្រសួងឃោសនាការ
លេខ ២៣៣ ចុះថ្ងៃទី ៣ មីនា ១៩៥៥

បោះពុម្ពលើកទី ៣

រក្សាសិទ្ធិ

ព.ស. ២៤៩៨
គ.ស. ១៩៥៥

# អារម្ភកថា

ហេតុដែលនាំឲ្យខ្ញុំរៀបរៀងច្បាប់គោរពមាតាបិតា, កិរិយាបំពេញជីវិតដោយកម្រ នឹងពុទ្ធប្រវត្តិនេះឡើង ព្រោះ:

១–យល់ឃើញថា បុត្រធីតាទាំងឡាយត្រូវតែគោរពមាតាបិតារបស់ខ្លួន ខានពុំបាន;

២–យល់ឃើញថា ពុទ្ធបរិស័ទគប្បីដឹងប្រវត្តិនៃព្រះពុទ្ធជាបរមគ្រូ;

៣–យល់ឃើញថា នឹងរក្សាទុកនូវពាក្យកាព្យឃ្លោងដែលជាស្នាដៃនៃបុព្វបុរសរបស់យើងកុំឲ្យបាត់;

៤–យល់ឃើញថា នឹងជួយផ្សាយនូវអក្សរសាស្ត្ររបស់ជាតិឲ្យមានតាំងនៅជាស្ថាពរតរៀងទៅ ។

លុះរៀបរៀងរួចហើយ ខ្ញុំបានយកទៅជូនលោក ឧត្តមប្រឹជា ពប-ពិន នាយការិយាល័យនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ឲ្យជួយពិនិត្យ, លោកនេះបានជួយពិនិត្យកែសេចក្ដីខ្លះនឹងតម្រូវតាមក្បួនកាព្យ ហើយខ្ញុំបានជូនសៀវភៅនេះដល់ចៅកែ ជួ-តិចស្រេង នឹងអ្នកស្រី (ឧបាសិកា) ង៉ូវ-រួចលង់ ជាស្វាមីភរិយា នៅគេហដ្ឋានលេខ ២០ ខាងកើតផ្សារធំថ្មី រុក្ខវិថីខេមរៈភូមិន្ទ ១៨៦ ទល់មុខហាងអាហារធំកុង ក្រុងភ្នំពេញ ព្រមទាំងលោកយាយ (ឧបាសិកា) ពិឆ នៅគេហដ្ឋានលេខ ១៨០ វិថីព្រះបាទសីហនុ ក្រុងភ្នំពេញ ដែលពេញអធ្យាស្រ័យនឹងធម្មកថា ឲ្យបោះពុម្ពតាមត្រូវការ ។

នៅថ្ងៃអាទិត្យ ៧ រោច ខែភទ្របទ ឆ្នាំមមីឆស័ក ពុ.ស.២៤៩៧ / គ.ស.១៩៥៤

បណ្ឌិត អ៊ូរ-ប៊ុន

# ឧទ្ទិសកថា

ឧបាសក ជូ-តិបស្រេង ឧបាសិកា នីវ-រួចលន់ ជាស្វាមីភរិយា, ឧបាសិកា ពិន, យើងខ្ញុំបានព្រមព្រៀងគ្នាបរិច្ចាគហិរញ្ញវត្ថុបោះពុម្ពធម្មកថានេះទុកជាធម្មទាន នៅឱកាសធ្វើបុណ្យរំលាយសពព្រះតេជព្រះគុណព្រះនាម ក្រួច-មុី ចៅអធិការវត្តគោកកាក ឃុំគោកគ្រប់ ស្រុកកណ្ដាលស្ទឹង (កណ្ដាល) ជាគ្រូរបស់យើងខ្ញុំផង ទុកធ្វើជាធម្មទាននៅក្នុងឱកាសណាមួយដែលគួរនឹងធ្វើផង, ព្រោះយល់ឃើញថា ការឲ្យទានធម៌ជាទានមានផលច្រើនជាងការឲ្យទានទាំងពួង ។

យើងខ្ញុំសូមឧទ្ទិសភាគផលនៃធម្មទាននេះ ចំពោះបុព្វការីជនទាំងឡាយ មានមាតាបិតាជាដើមដែលទទួលមរណកាលទៅហើយ សូមអ្នកមានគុណទាំងនោះ ទទួលអនុមោទនាយកភាគផលនៃធម្មទាននេះ តាមពេញអធ្យាស្រ័យ ហើយសូមឲ្យបានសម្រេចសេចក្ដីសុខ-ចម្រើនតាមប្រាថ្នារបស់អ្នកមានគុណទាំងនោះ, ចំណែកខាងយើងខ្ញុំក៏សូមឲ្យបានសម្រេចផលជាទីគាប់ចិត្តរៀងរាល់ជាតិ ដរាបដល់បានសម្រេចព្រះនិព្វាន ។

# បញ្ជីរឿង

រឿង | | ទំព័រ


ច្បាប់គោរពមាតាបិតា .................. ១

ការិយាចិញ្ចឹមជីវិតដោយកម្រ ............ ៧

ពុទ្ធប្រវត្តិ ....................... ១១

# ច្បាប់គោរពមាតាបិតា

បទកាកគតិ

កូមិធម៌កូមិសុខ កូមិបុណ្យទៅមុខ កូនរកមិនត្រូវ មិនស្តាប់ពាក្យ ទេសនាម៉ែឪ តែងបណ្ដុលផ្លូវ ប្រាប់កូនប្រុសស្រី ៗ តែកូនមិនជឿង ច្រើនណាស់តែទឹង នឹងម៉ែឪស្ដី តាមពិតគួរស្ដាប់ សូរស័ព្ទសំដី លោកហើយគប្បី គោរពបូជា ៗ ដូចស្ដាប់ព្រះសង្ឃ លំអុតឱនអង្គ បង្គំវន្ទា ព្រះពុទ្ធដាក់ក្បួន ប្រដួនទាមា ឈ្មោះថាបុញ្ញ- ចារ្យ (គ្រូខាងដើម) ៗ សម្រាប់ទូន្មាន កូនចៅគ្រប់ប្រាណ ឲ្យបានយ៉ាងថ្នម កុំឲ្យដើរលេង ជាល្បែងគេខ្ពើម កុំឲ្យរើម សប្បាយជ្រុលពេក ៗ ពេលយប់ព្រលប់ មើលការឲ្យគ្រប់ ទុកដាក់ហើយដេក ហើយក្រោកពីយប់ ប្រារព្ធពុនរែក កុំឲ្យទាស់ក្អក អ្នកផងទាំងឡាយ ៗ មើលគេអ្នកមាន គេមិនអត់ឃ្លាន មានកាសប្រាក់ចាយ ព្រោះគេបានស្ដាប់ នូវច្បាប់ឪពុក ម្ដាយ ទើបបានសប្បាយ នាលោកនេះហោង ៗ នេះធម៌ទេសនា របស់មាតា នឹងបិតាផង បើកូនណាស្ដាប់ នូវច្បាប់គន្លង កូននោះលែងគង់ ចាស់ផងស្ងួនភ្ជា ៗ ព្រះពុទ្ធដាក់ឈ្មោះ បាលីពីកោះ បុត្តទេព (ទេវតាខាងដើម) អ្នកផ្ដើមរក្សា បុត្រីបុត្រា ហៅទេវតាផ្ទះ ៗ គឺម្ដាយឪពុក ជាអ្នកម្ចាស់សុខ កូនមិនសំពះ ម៉ែឪទូន្មាន ល្ងានពានបង្ឈ្នះ សត្រូវនឹងព្រះ កន្ទោងអាត្មា ៗ

ប្រុសក៏យ ទឹងឪពុកម្តាយ ស្រែកហៅទេវតា អំពីខាងក្រៅ
ជឹងនៅឯណា ឈ្មោះទឹងទេវតា គឺម៉ែឪឯង ៗ តែងតែលំបាក
ក្រីក្រតោកយ៉ាក ជាតិនេះឃើញស្តែង ហើយទៅរងទុក្ខ ខានមុខពុំលែង
លុះក័យទើបស្វែង រកហោរគ្រូទាយ ៗ ហោរបូកលេខផៅ
តាមក្បួនឃើញថា ខុសគ្រូខាងម្តាយ ឬខាងឪពុក កុំទុកយូរឆ្ងាយ
ត្រូវលៀងលោមថ្វាយ គ្រូពីរទើបជា ៗ ហោរទាយត្រូវណាស់
កូនស្តាប់មិនច្បាស់ បែរទៅវន្ទា អ្នកតាអារក្ស ទេព្រក្សល្បាក់សា
ម៉ែឪអាត្មា មិនថ្វាយបង្គំ ៗ មិនលន់តួទោស អំពើកំហុស
ជូនបំណាំទី ធ្វើសម្ពាយ មកថ្វាយបង្គំ ខមាលាសុំ
ឲ្យអត់ទោសពៃរ៍ ៗ ដូច្នេះមិនធ្វើ យកបេកទៅធ្វើ គល់ឈើក្នុងព្រៃ
ដំបូកអ្នកតា វន្ទាសព្វថ្ងៃ ធូបបីសរសៃ និយាយសុំសុខ ៗ
ម៉ែឪមិនឲ្យ ព្រោះជឿចិត្តខ្វាយ បោលគុណនៅមុខ ច្រើនជឿបែបនេះ
ដូច្នេះគ្រប់ស្រុក ត្រង់ម្តាយឪពុក បោះបោលទទេ ៗ ម្យ៉ាងទៀតធ្វើបុណ្យ
ច្រើនតែបោលគុណ គ្មានគិតរិះរេ បោលទៅតែវត្ត ម្តាយអត់ទទេ ព្រោះ
ជឿតាមគេ រកបុណ្យខាងក្រៅ ៗ ដើមបុណ្យលើផ្ទះ ខ្លួនកើតទាន់ព្រះ
កន្ទោងគង់នៅ បានត្រីត្រកាល ក្បាលឲ្យម៉ែឪ កណ្តាលនាំទៅ
យកបុណ្យឯវត្ត ៗ កណ្តាលសុទ្ធឆ្ងាញ់ សាច់ពោះពងខ្លាញ់ ឆ្ងាញ់លោក
បុកមាត់ ម៉ែឪជព ទន្តាបាក់ម៉ត់ ទុកក្បាលឲ្យគាត់ ក្បាលសុទ្ធតែឆ្អឹង ៗ

នេះហៅបុណ្យខុស ទាំងស្រីទាំងប្រុស ខ្ញុំប្រាប់កុំខឹង ម៉ែឪនៅរស់
ប្ដូរអស់លោកប្រឹង ដេញគាត់នៅរឹង បានឆ្ងាញ់ពិសា ។ ខ្លះជឿបុណ្យខ្លាំង
យួរម្ហូបទាំងឆ្នាំង យកទៅវត្តរាំ ម៉ែឪអត់ឃ្លាន ចង់បានណាស់ណា៎
ក្មួយសួរកូនថា មានសល់ឬទេ ។ ព្រឹកឡើងឃ្លានបាយ ញ័រពោះញើស
ខ្លាយ ឃើញសម្កេគ កូនឆ្លើយរឹងប្កាន មិនបានសល់ទេ ខ្ញុំស្ទើគ្រាន់តែ
ទៅវត្តទេកូរ ។ ឪពុកសួរថា បើដួសកាលណា បែកឪខ្លះទៅ
កូនខ្លះឆ្លើយប្រាប់ ថាបាបណាស់ឪ គេថាមិនត្រូវ ឪស៊ីមុនលោក ។
ម៉ែឪហាស់ៗ ព្រឹកឡើងឃ្លានណាស់ គួរឲ្យវិយោគ ឪតារពិសា
កូនថាមុនលោក ពុំបានបរិភោគ គេឲ្យបាបផង ។ នេះបុណ្យផ្កាប់មុខ
ឬបុណ្យពោលស្រុក ព្រោះដើរផ្លូវឆ្គង បុណ្យមិនត្រកាល
វិសាលឡើយហោង ព្រោះដើរកន្លង ឲ្យម៉ែឪអត់ ។ ពួកជនឈ្លានពាន
មិនបេះធ្វើទាន ច្រើនធ្វើទានក្បត់ សទ្ធាមិនជ្រៅ ជ្រុលទៅតែវត្ត
ឲ្យព្រះដើមអត់ ស្រែកឃ្លានពេកក្រៃ ។ នេះឯងខុសណាស់ មកពីមិន
ច្បាស់ ច្បាប់ធម៌វិន័យ បានជាប្រព្រឹត្ត គំនិតព្រៃផ្សៃ បន្ទោកដម្លៃ
នៃអ្នកមានគុណ ។ យល់ខុសស្រឡះ ព្រោះមិនស្គាល់ព្រះ
មិនច្បាស់ដើមគុណ អ្នកប្រាជ្ញបុរាណ ថាបានធ្វើបុណ្យ ត្រូវថ្វាយព្រះមុន
សឹមថ្វាយព្រះសង្ឃ ។ រៀបចង្ហាន់ព្រះ បូជាសំពះ មើលព្រះឲ្យគ្រង់
ប្រាជ្ញប្រាប់ជាបែប សង្ខេបតម្រង់ វេរភត្តថ្វាយសង្ឃ ត្រូវថ្វាយព្រះមុន ។

គឺជូនភោជនា មាតាបិតា បូជាតបគុណ សឹមថ្វាយព្រះសង្ឃ ទ្រទ្រង់សីលបុណ្យ ព្រោះម្ដាយមានគុណ រកអ្វីស្មើគ្មាន ៗ ត្រូវធ្វើបុណ្យ ខ្មើត ម៉ែឪស៊ីកើត កំពុងស្រែកឃ្លាន ម៉ែឪរស់នៅ កូនត្រូវធ្វើទាន បំបាត់ក្ដីឃ្លាន ហៅធ្វើបុណ្យខ្មើត ៗ ហៅបុណ្យខែក្ជឺ កុំចាំគាត់ឈឺ បរិភោគលែងកើត ជូនគាត់កាលជា ហៅថាបុណ្យខ្មើត គាត់បរិភោគកើត បានជាងរនោច ៗ លុះបាត់ជីវិត បុណ្យខែងធិត ដូចថ្ងៃ ១០ កេច កូនចៅទាំងឡាយ យកបាយឲ្យខ្មោច ម៉ែឥតប្រយោជន៍ ខ្មោចណាបេះ ស៊ី ៗ កត្តិកមាសា ចេញខ្យល់ហើ ត្រជាក់ពេញទី មិនគិតរកក្លួយ បាន ១ ឬ ២ ទាំងមិនសាមគ្គី រកពូកជូនគាត់ ៗ ត្រូវរករបស់ ជាស្នូបតានរស់ ដណ្ដប់ជូនគាត់ កុំចាំជាប់ខ្យល់ ទើបខ្វល់គ្រប់មាត់ រកស្នប់រុំគាត់ ដណ្ដប់ឲ្យខស ៗ ឲ្យក្ដីងគ្រែកអរ ទទួលអំណារ មិនដឹងត្រូវសុខ ម្ដេចមិនខ្វល់ខ្វាយ ជូនម្ដាយកាលរស់ ម្ដេចចាំខ្យល់អស់ ទើបធ្វើឲ្យឡារ ៗ កាលគាត់រស់នៅ ព្រឹកល្ងាចក្ដួលក្ដៅ ស្រែកឃ្លានអស្ចារ្យ មិនគិតជួយគាត់ ឲ្យអត់អាហារ ឲ្យតែធ្វើការ ចាំផ្ទះឲ្យគេ បំណាំត្រីសាច់ ចង់ស្មើរប្រកាច់ អត់ជូនគាត់ទេ ដល់ឈឺផ្ដត ៗ ម្ហូតៗ ទើបរេ ដេកផ្ទះទើបគេ ជូនទំបំណី ៗ ទាំងជិតទាំងឆ្ងាយ មូលមកសួរម្ដាយ ទាំងប្រុសទាំងស្រី ទុរេនទំប៉័ង សម្រាំងថ្មី ៗ ម្ដាយឈឺលេងស្ដី រងគ្រាមស្ងួតក ៗ កូនហៅថាម៉ែ! ម៉ែស្គាល់ខ្ញុំទេ?

បានចំណីល្អ ម្តាយពោលខ្សាវ ៗ គ្រាវ ៗ ធ្វើយក ថាគើឯងមក
ម៉ែអរណាស់ណា ៗ កាលម៉ែមិនឈឺ មិនមានជម្ងឺ នោះកូនពល់គ្នា
មិនអាណិតម៉ែ លុះម៉ែជរា ទើបកូនពល់គ្នា មករុញបញ្ជួល ៗ
ឪម៉ែស្លាប់បាត់ ទើបកូនប្រវាត់ ប្រាប់ញាតិត្រកូល ឃោសនាជនជាន
គ្រៀងលានឲ្យចូល មកជុំប្រមូល ធ្វើបុណ្យឲ្យខ្មោច ៗ ខែផល្គុនចែត្រ
ថ្ងៃក្តៅក្រៃឡែត ឆ្ងាយទឹកហិនហោច ម៉ែឪចាស់ ៗ ក្តៅណាស់អណោច
មិនរកទឹកស្រោច ឪពុកម្តាយសោះ ៗ មិនមានបូមបាក់ មិនដងទឹកដាក់
ពាងដោយសង្គ្រោះ ដល់ពេលគាត់ស្លាប់ នោះស្រាប់តែស្មោះ
អប់ទឹកក្អមនោះ ហៅលើកបន្លាស ៗ ម៉ែឪរស់នៅ មិននាំគ្នាទៅ
ធ្វើការប្រវាស់ ដាក់វេនក្រោយមុន តបគុណគាត់ចាស់
ស្លាប់ហើយធ្វើណាស់ ដណ្តើមគ្នាផុស ៗ ដូចស្រោចគល់ឈើ
ដាក់ទឹកផេផើ មិនដឹងត្រូវខុស ទើបកូនវង្វា ស្មាណាទោសខុស
ម៉ែឪនៅរស់ មិនដែលវង្វា ៗ កាលមានជីវិត នោះកូនគ្មានគិត
ម្តេចរូបវេទ ម្តាយឪពុកទូន្មាន កូនគ្មានបូជា បំពេញសទ្ធា
ឲ្យម្តាយស្មាទាន ៗ ស្តាប់ធម៌ទេសនា ឲ្យម្តាយជ្រះថ្លា រកស្លូតនិញ្ញន
ប្រើម្តាយធ្វើខ្ញុំ នៅចាំបន្ទ្រាន ឲ្យទៅស្មាទាន ឲ្យឆាប់មកវិញ ៗ
មើលកូនយកហៅ ខែនេះកូនទៅ ដកស្ទូងស្រែមិញ ម្តាយទៅរូតរះ
មកផ្ទះបំណេញ ម្តាយប្រាប់ទៅវិញ អញស្តាប់លោកទេសន៍ ៗ

កូនជាស្ងួនហើយ ស្ដាប់ចុះម៉ែអើយ ! ខែនេះកុំធ្វេស គណ្ដាប់ក្រៀមហែង

ម៉ែឯងប្រហែស ដើរស្ដាប់លោកទេសន៍ សំណាបចុកថ្កាល ។

១ ខែ ៤ សីល គេថាម្ដាយខ្ជិល ពួកកូនត្រកាល ទុកម្ដាយគ្រាន់ប្រើ

បម្រើធូរស្រាល ម្ដាយខូចខួរក្បាល លែងស្គាល់ពុទ្ធដីកា ។

ស្លាប់ទៅជាទស គេដុតឆេះសុស ហើយគេនាំគ្នា រើសធាតុដាក់ថៅ

ក្អកស្មោតនិច្ចា ហៅញាតិកា ហែធាតុទៅវត្ត ។ ឲ្យនៅស្ដាប់ធម៌

ឲ្យធាតុត្រេកអរ ព្រោះលែងប្រើគាត់ កាលម្ដាយរស់នៅ មិនឲ្យទៅវត្ត

ដុតឆេះខ្លោចម៉ត់ ទើបឲ្យទៅថ្កាន ។ ហេតុនេះអ្នកអើយ! កុំធ្វើព្រងើយ

ប្រុសស្រីគ្រប់ប្រាណ បម្រើមាតា បិតាកុំខាន ទើបសុខក្សេមក្សាន្ត

បានអាយុវែង ។ កុំគប្បីធ្វេស កុំឈ្លោះបបេស នឹងម៉ែឪឯង

ជាតិនេះជាតិក្រោយ ទុក្ខសោយមិនលែង ព្រះពុទ្ធសំដែង ច្បាស់ឥត

សង្ស័យ ។ អវិចិនរក ទំរួបទុក្ខ យូរយារពេកក្រៃ អាយុមួយកប្ប

គ្មានរាប់ខែថ្ងៃ បើមាននិស្ស័យ ទើបរួចមកបាន ។ មកកើតជាប្រេត

រួចទើបអណ្ដែត កើតជាតិរច្ឆាន លុះអស់វេរា ទើបជាមនុស្សបាន

ខ្វិនខ្វាក់ក៏មាន គថ្លង់ឃ្លង់ស្រែង ។ ជាច្ពួតច្រើនជាតិ ព្រោះទោសប្រមាថ

ឪពុកម្ដាយឯង មាក់ងាយដល់ព្រះ ក្នុងផ្ទះឥតក្រែង ទើបបានចំបែង

វេងទុក្ខបែះណា ។ ថ្ងៃឯចប់ប៉ុណ្ណោះ សូមបញ្ចប់ស្ទះ សង្ខេបកថា

ថ្ងៃឯមកប៉ុន្មាន សូមបានផលា ដូចក្ដីប្រាថ្នា ដល់ព្រះនិព្វានហោង ។

អវសាន

# កិរិយាបញ្ចមជីវិតដោយកម្រ

បទព្រហ្មគីត

សូមក្រើនដល់បុរស ស្ត្រីទាំងអស់គ្រប់ៗប្រាណ តូចធំទាំងប៉ុន្មាន
ត្រូវប្រដៅខ្លួនឲ្យហើយ ៗ កាលនៅលីវកម្លោះ ក្រមុំនោះអ្នកនាងអើយ
ប្រឹងប្រែងកុំកន្ដើយ កុំព្រងើយត្រូវឧស្សាហ៍ ៗ កុំអាងថានៅក្មេង
ដើរតែលេងកាត់រកគ្នា បៀរប៉ោជ្លួកញ្ញា សេពសុរាទឹកត្នោតជូរ ៗ
ប្រព្រឹត្តអនាចារ ដើរបោលការគ្មានគិតគូរ ដល់មាន់លេងឡូតូ ដើរ
មើលពំប្ដស្ដាប់ច្រៀង ៗ មានប្ដីប្រពន្ធហើយ កុំធ្វេសឡើយត្រូវផ្ចាត់ផ្ចៀង
គេហៅទៅកំព្រៀង ត្រូវប្រកែកកុំដើរលេង ៗ យើងដេកពីព្រលប់
កណ្ដាលយប់ក្រោកគិតក្រែង ថែទាំទីកន្លែង ផ្ទះសម្បែងប្រុងប្រយ័ត្ន ៗ
ធ្វើឲ្យប្រពន្ធកោត មនុស្សស្រីឆោតបេះប្រណិប័តន៍ ដិតព្រឹកភ្ញាក់ឡើង
ចាត់ ធ្វើរបររបស់ខ្លួន ៗ រក្សាទ្រព្យទុកដាក់ ស្រូវមាសប្រាក់ប្រឹងថែធួន
យើងតែងមានកូនសួន កុំប្រហែសណាអ្នកអើយ! ៗ មានដីជុំវិញផ្ទះ
ដាំអ្វីខ្លះកុំខានឡើយ បន្ទុកអន្ទុក់ហើយ ចេកអំពៅត្រាវដំឡូង ៗ
ស្វាយខ្នុរល្មុតសេដា ទៀបម្លូស្វាត្របែកដូង បានគ្នាជាដំបូង
គោងបណ្ដុះមេគំនិត ៗ ដល់យើងមានកូនមក សត្វចូលជ្រកផ្ញើជីវិត
យើងស្រួលក្នុងគំនិត ស្រណុកគិតព្រោះប្រុងទុក ៗ បើកើតកូនប៉ុន្មាន
វាចង់បានគ្រឿងគ្រប់មុខ វាការម្ដាយឪពុក វារំអុកតារតេជ្រមាស ៗ

ទារហូលព្រៃឡាឡាញ់ ទារស៊ីឆ្ងាញ់ចំណីពាស កូនស្រីទារពេជ្រមាស
យើងមិនបានទិញឲ្យវាៗ កូនប្រុសមួកស្បែកជើង ខោអាវឡើងគេខុសគ្នា
យើងរាស្ត្រជាតិអ្នកជា មានទ្រព្យបែកឲ្យកូន ៗ ម៉ែឪមានមុខនោះ
កូនសង្គ្រោះមិនសាបសូន្យ បើយើងប្រដៅកូន កូនកោតខ្លាចអំណាច
យើង ៗ កូនកើតតាំងពីតូច ឃើញឪខូចភ្នាក់ដៃជើង កាត់ពូជមកមិនលើក
ព្រោះតែយើងធ្វើទុកមក ៗ បើយើងមិនលះលេង តាំងពីក្មេងលះលែលក
ខំធ្វើខំប្រឹងរក ឥតខំនេះប្រឹងឧស្សាហ៍ ៗ ដូចពូជឬស្សីស្រុក
ដុះស្រណុកត្រង់ល្អជា ខ្ពស់ស្អាតតាម ៗ គ្នា គេត្រូវការចង់បានណាស់ៗ
បើពូជឬស្សីព្រៃ ដុះពេញដីចង្អៀតក្រាស់ បន្លាណែនណាន់ណាស់
ឆ្ពក់ទាញគ្នារៀបតាមពូជ ៗ បានត្រង់បុងបំផុត គល់មិនពត់កាត់កាច់ខូច
កើតកូនមកកាត់ដូច ខឹងទឹងកូនស្ដីមិនស្ដាប់ ៗ មិនកាត់ពីណាទេ
កាត់ពីមេបាស្រាប់ ព្រះអង្គទេសនាប្រាប់ ឲ្យប្រដៅខ្លួនបានសិន ៗ
កុំធ្វើឫកកិរិយា ខុសមាត្រាគិតឲ្យឆ្អិន រៀបចំខ្លួនឲ្យប៉ិន ទើបបង្កាត់ទៅ
ជាកូន ៗ ទើបពេញជាបិតា ប្រសើរជាពុំសាបសូន្យ កាត់បានមក
ជាកូន សឹងខ្ពង់ខ្ពស់ដូចគេស្ទួយ ៗ ពួកពាលមានច្រើនណាស់ ទាំង
ក្មេងចាស់នាំគេព្រួយ ព្រឹកឡើងនៅរង្វើយ ផឹករលោភដោយទៀមស្រា ៗ
ជនខ្លះលីវកម្លោះ ដើរម៉េះម៉ោះសេពសុរា ជនខ្លះចាស់សារសា
នៅឡូឡាទ្រេតតាមផ្លូវ ៗ មានកូនចៅសន្ធឹក មិនប្រែឫកឲ្យត្រឹមត្រូវ

ធ្វើស្រែពលរដ្ឋ គ្មានសល់ស្រូវស៊ីដល់ខួប ។ ព្រោះធ្វើសោះតែខាន
គ្មានបង់បានមករួមរួប រវល់កាត់ទៅជួប រកពួកម៉ាកពាលអសោចិ៍ ។
ផ្ទះលេចឃ្លានដញ្ញាំង កន្ទេលបាំងក្រហិនហោច ច្រើនដើរឥតប្រយោជន៍
មិនខ្មាសគេអ្នកក្នុងស្រុក ។ មាន់ងាវគេភ្ញាក់រឹង ឯងនៅប្រឹងដេកស្រមុក
គេភ្ជួរស្រែអែអុក អស់ទាំងស្រុកមាត់អឺងកង ។ ឯងដេកទម្រន់ណាស់
ប្រពន្ធដាស់បង់ធាក់ផង ធ្វើការចាំហៃហង ច្រើនលែនលនដេកផ្ទុំខ្ពុយ ។
ទំនេរខ្លួនពេកណាស់ អាចម៍គោក្រាស់នៅបែកស្អុយ ខែប្រាំងដីគោកហុយ
មិនលើកភ្លឺឲ្យជាប់ទឹក ។ មកពីលេងផ្ទះគេ ហួសទៅរេរកស្រាផឹក
នេះពួកជនប្រមឹក មកពីផឹកដេរឆោឡោ ។ កូនស្រីក្រមុំគ្រាន់ គ្មាន
សៀកវណ្ណខ្លួនធំប៉ោ កូនប្រុសគ្មានអាវខោ ឪពុកគិតតែកើបស្រូវ ។
ទៅសងបំណុលស្រា នៃអាគ្មានពលរដ្ឋ ឡូឡាមាត់ញុំញ៉ូវ គ្រាន់តែ
ឪគាត់បំផ្លាញ ។ ម៉ែឪគេជិតខាង មានសំណាងសាងបង្ហាញ ដៃជើង
គេមិនក្រាញ មិនស្ទុគ្រស្ទាញទាំងតូចធំ ។ ម៉ែឪឯងយ៉ាំងហ្នឹង កុំរំពឹក
បានរៀបចំ បើកូនវាប្រឹងខំ វាហ៊ានជៀលមារយាទឪ ។ ថាដើរតែផឹក
ស្រា មកឡូឡានេះមិនត្រូវ ស្រវឹងហើយស្ងៀមនៅ ក្រពីឪមកដល់ខ្ញុំ ។
ម៉ែឪបែបយ៉ាំងហ្នឹង កុំរំពឹងថាគុណធំ គុណតូចប៉ុនដីដុំ ព្រោះគ្មានធម៌
សង្គ្រោះកូន ។ ហេតុនេះស្តាប់ឲ្យជាក់ តោងតែភ្ញាក់ប្រឹងល្អះល្អូន
ប្រដៅខ្លួនមុនកូន ឲ្យបានបទជាឡាក់ឋាន ។ ប្រឹងកែមារយាទទៀត

ដែលហោលម្យៀតទាំងប៉ុន្មាន ទើបពូជយើងថ្កើងថ្កាន កូនកំអានសីថា

ឲ្យ ៗ ម្យ៉ាងទៀតពួកស្រី ៗ ដែលមានប្ដីកុំបណ្ដោយ ស្រីខ្លះមារយាទ

ផ្ដាយ ផ្អែកជីវិតលើតែប្ដី ៗ ប្ដីទៅស្រែបាត់ស្បូវ ដេកទបកូនក្របុះដី

ប្រមុះយកដៃឈ្មី ហារមាត់ស្វាបមួយចំអាម ៗ ថ្ងៃរះទើបក្រោកឡើង

ធ្មើរសើងម៉ឺងក្អែករហាម ពត់ខ្លួនអាកអើមអាំម មិនទាំងលុបមុខក្រញុះៗ

អង្គុយមាត់ដណ្ដើរ ស្វាបបណ្ដើរអួសគូថចុះ គំនិតមិនមានផុះ តែ

មាត់ប៉ុនដេរឈ្មោះណាស់ ៗ បើស៊ីមើលមិនទាន់ មាត់រន្ទាន់ញាប់រហ័ស

ពេហារក៏ប៉ិនណាស់ តែប៉ិនខាងបន្ទោសប្ដីៗបើមានគេប្រជុំ ឬជំនុំពីរឿងអ្វី

អង្គុរហោលនៅដី ឈរស្ដាប់គេមាន់ស៊ីអស់ ៗ បើបុកអង្ករស្រូវ

ខ្ចាយបេញទៅខ្ចូចរបស់ ឥតស្ដាយឥតខ្វាបអស់ ឈ្លួសដីលុបខ្វាបគេ

ទាន់ ៗ របស់ប្ដីរកបាន ទាំងប៉ុន្មានអស់រលួសពាន់ ដល់ដៃស្មើរមិនទាន់

ព្រោះចំពាក់ជឿគេស៊ី ៗ បែបនេះមិនមែនស្រី ចាស់លោកស្ដីហៅថាញី

រកបានមិនគ្រាន់ស៊ី គ្មានសន្សំបង្ការចាស់ ៗ ពីក្មេងកំឡាំងមាន

ឃើញរកបានចាយធំណាស់ ចាំមើលដល់ខ្លួនចាស់ ចយកំឡាំងអាង

អ្នកណា?

ដែលខ្ញុំក្រើនរំលឹក ព្រោះខ្ញុំនឹកជាតិខេមរា ចង់ឲ្យបានថ្ងៃថ្លា

និង្ហិតាប៉ុណ្ណោះហោង ៗ

អវសាន

# ពុទ្ធប្រវត្តិ

នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យ ។

ហើយសូមថ្លែងរឿងពុទ្ធប្រវត្តិ ជាពាក្យកាព្យដោយសង្ខេបដូចតទៅនេះ

បទពាក្យ ៧

កាលព្រះសិទ្ធត្ថថ្ងៃប្រសើរ ទ្រង់ព្រះដំណើរចាកក្រុងក្រៃ
ដើម្បីបព្វជ្ជានាព្រឹក្សព្រៃ ដោយលះព្រះទ័យឥតសារ៉ា ។
ព្រះនាងពិម្ពាភ្ញាចាកផ្ទំ មិនឃើញបរមភស្តា
ទ្រង់ព្រះកន្សែងសោយសោកា ដោយព្រះវាចាទំនួញថ្លែង ។
ថាឱ ! ភស្តាពិម្ពាអើយ ម្តេចឡើយនិរាសចាកកន្ទែង
ឲ្យខ្ញុំកំព្រានៅម្នាក់ឯង កណ្តាងនឹងកូនស្ងួនអាល័យ ។
ម្តេចទ្រង់មិនស្តាយបុត្រពន្លក ដែលទើបកើតមកបានមួយថ្ងៃ
មិនសមបើលះព្រះហឫទ័យ ដាច់ឥតអាល័យអ៊ីម្ល៉េះណា ។
នុះឱ ! រាហុលកូនប្រិមប្រិយ អ្នកទើបកើតថ្មីរូបល្អថ្លា
គួរឲ្យអ្នកផងកើតស្នេហា មិនសមបើបាមិនស្គាល់ឪ ។

## បព្វជ្ជាបរិច្ឆេទ

កាលព្រះមហាសត្វមានបុណ្យ ទ្រង់គង់ពាជីស្តេចចេញទៅ
ចាកព្រះនគរកាន់ព្រៃជ្រៅ ដោយនូវឆ្នេះគម្រប់បី ។
ទ្រង់ហោះរំលងព្រះរាជវាំង នោះមារមកវាំងយ៉ាងណាក្តី

កំឃាត់មិនឈ្នះព្រះចក្រី ដោយបុណ្យបារមីពីបុព្វជាតិ ។
ព្រះពោធិសត្វកាត់ស្រុកទៅ ដល់ទីព្រៃជ្រៅហើយខ្លីឃ្លាត
ទ្រង់ចុះបាកៈសះយាងគរគាត នរនាថឈប់នៅក្បែរនទី ។
មាននាមហៅថាអនោមា ព្រះបមភាពទ្រង់ឃ្លាតខ្លី
កាត់ព្រះកេសាដោយសេរី ដើម្បីទ្រទ្រង់ភេទបព្វជ្ជា ។
ហើយទ្រង់ត្រាស់ហៅនាយឆន្នៈ ដែលតាមការរៈទ្រង់ផ្ដាំថា
នែឆន្ន ! ចូលទៅទូលបិតា ថាយើងសុខឥតទុក្ខឡើយ ។

## ទុក្ករកិរិយាបរិច្ឆេទ

កាលព្រះមហាសត្វជាមង្គុដ ខ្ពស់ផុតត្រៃលោកទ្រង់ផ្នួសហើយ
ទ្រង់ព្យាយាមតឹង ឥតផូរឡើយ តម្រង់ទៅត្រើយព្រះញាណធំ ។
ទ្រង់គង់ក្រោមម្លប់ពីងសាខា ក្នុងព្រៃព្រឹក្សាស្ងាត់ទូរគមន៍
គង់ផ្ទាលដីថ្កូបន្ទោះក្ដី ហៅថាធ្វើទុក្ករកិរិយា ។
ទ្រង់ដាក់ធុរៈប្រដៅចិត្ត ដោយទ្រង់ប្រព្រឹត្តទូវក្រឹត្យា
ពែនខ្នាស់ព្រះបាទខ្វែងលើគ្នា ប្រាប់ថាយើងឯង ៧ ថ្ងៃ ។
បុកកោយស្រពាន់តែដើងចុះ ចិត្តនៅក្នុងនោះកុំសង្ស័យ
ធ្វើកម្មដ្ឋានឲ្យកើតញេយ្យ ញាណដ៏ប្រពៃណាចិត្តអើយ!
ចំណែកដៃឯងតម្រួតគ្នា ពោះខ្យល់រសាធ្វើព្រងើយ
៧ថ្ងៃនេះមិនក្រោកឡើយ ភ្នែកអើយកុំឲ្យយើងមិនដេក ។

ពោះសោកចូរអ្នកទ្រាំកុំឃ្លាន ដែលធ្លាប់តែមានធ្លាប់តែក្រោក
កាយឯងអន្ទុយកុំញ័រពេក ពោះឃ្លានពោះស្រែកយើងមិនក្រោក ៗ
លុះដល់គម្រប់ ៧ ថ្ងៃ មិនឃើញធម៌ថ្ងៃទ្រង់ស្វែងរក
ផ្លាស់កន្លែងទៀតទំលៃលក ទ្រង់ចូលទៅជ្រកម្លប់ដទៃ ៗ
ទ្រង់ខ្ជាន់ចិត្តឲ្យសប្បាយ បំរើនមេត្តាជាប្រក្រតី
ថាចិត្តឯងអត់កុំខ្ជិលអ៊ី យើងខ្ពីមកពីណា ចិត្តណា ៗ
កាលមុនយើងមកយើងឃើញខ្លួន ទេវទូតទាំងបួននៅព្រឹក្សា
និមិត្តរូបចាស់រូបឈឺផ្សា រូបស្លាប់អាកើតទុក្ខភ័យ ៗ
លុះឃើញបព្វជិតភេទអ្នកបួស ចិត្តយល់ថាហួសពីកពាក្រៃ
មានតែភេទនេះទើបប្រពៃ ផុតភ័យគឺកើតចាស់ឈឺស្លាប់ ៗ
ព្រោះគ្មានបំពាក់នឹងទ្រព្យធន គ្មានកូនប្រពន្ធញាតិបង់ចាប់
ស្វែងរកនិព្វានស្រុកគ្មានស្លាប់ ចូរចិត្តអ្នកស្តាប់យើងខ្ជាន ៗ
បេះបួតស៊ូកឈើសោយសិនទៅ សុខចិត្តតែនៅទ្រាំអត់ឃ្លាន
យើងខំប្តូរយកព្រះនិព្វាន សុខធំលែងមានភ័យទៀតណា ៗ
អស្ចារ្យកាលព្រះពោធិសត្វ មហាបុរសរតន៍ទ្រង់សប្បាយ
ព្រះអង្គឥតផ្ទំលក់ពេលណា ក្រយាគ្មានសោយយូរឆ្នាំខែ ៗ
ស្គាំងស្គមស្រេមស្រមឃើញស្បែកឆ្អឹង សរសៃរគឹងសាច់ខ្មៅអែ
ហាលថ្ងៃភ្លៀងខ្យល់យូរឆ្នាំខែ លុះតែប្រាំមួយឆ្នាំមកដល់ ៗ

ហើយព្រះមហាសត្វទ្រង់ជ្រាបថា ទុក្ករកិរិយាមិនមានផល
ជ្រាបស្រេចសម្តេចព្រះទសពល ត្រឡប់ខ្វាយខ្វល់សោយក្រយា ។
កំណត់មួយថ្ងៃឆាន់មួយពុះ កុំឲ្យតឹងពោះអប្បប្រាជ្ញា
ពេលល្ងាចកុំឆាន់ស្រាលទាំព ស្វែងរកបញ្ញាពោធិញ្ញាណ ។
ថ្ងៃនីមកបោះៗផ្ទោះសេចក្តី ដើម្បីទៅមុខទុកនិទាន
កាលទ្រង់បានត្រាស់ច្បាស់ព្រះញាណ និទានពីនាងសុជាតា ។
ពេលមុនបានបន់អារក្សជ្រៃ ដោយន័យធ្លាប់ជឿជំនឿថា
អារក្សដើមជ្រៃជាទេវតា នាងបន់ប្រាថ្នាហេតុ ៣ យ៉ាង :
ហេតុ ១ ថាបើត្រូវមានប្តី ចិត្តឥន្ទ្រិយ៍លាសំណាង
ប្រុសចិត្តអាក្រក់កុំជិតខាង សូមលោកជួយនាងខ្ញុំឲ្យផុត ។
សូមឲ្យប្តីនោះលុះដោយធម៌ មានចិត្តស្មោះសរល្អបរិសុទ្ធ
ហេតុ ២ ថាសូមឲ្យបានបុត្រ ដោយពិតចំហុតកូនប្រុសមុន ។
ហេតុ ៣ សូមជួបតែអ្នកប្រាជ្ញ ជាអ្នកអង់អាចស្គាល់ទោសគុណ
បើបានដូចចិត្តថ្វាយទានមុន យកមកសងគុណលាបំណន់ ។
នាងសុជាតាបន់ទៅហើយ មិនបានយូរឡើយនាងស្រីគន់
បានប្តីចិត្តល្អដូចនាងបន់ បានកូនទាន់ហន់ប្រុសមុនផង ។
នាងជឿទេវតារុក្ខជ្រៃ នាងខំកែខៃពេកកន្ទង
ធ្វើមធុបាយាសល្អឥតហ្មង ប៉ុនប៉ងព្រឹកឡើងទូលទៅថ្វាយ ។

លាការថែរបន់បំណាន់នាង ដើម្បីកស្តុតានចិត្តស្រស់ស្រាយ
ដោយបានសម្រេចផលទាំងឡាយ ដែលខ្លួនខ្វល់ខ្វាយពីមុនហោង ។
ព្រឹកនោះគាប់ជួនជាព្រះអង្គ មកគង់ក្រោមដើមជ្រៃនោះផង
ដោយទ្រង់វិតក្កនឹកបំណង ប៉ុនប៉ងជាព្រះពុទ្ធពន្លក ។
ពេលនោះសុជាតាប្រិមប្រិយ ប្រើនាងទាសីឲ្យកាន់យក
អំបោសទៅបោសជ្រះលែលក រួចមកទើបទៅលាបំណាន់ ។
ទាសីស្រីនាងក៏ចូលទៅ ឃើញព្រះគង់នៅនាងភ័យស្លន់
ត្រឡប់ដំកបថាយើងបន់ ឥឡូវយើងទាន់ទេវតាហើយ ។
ទេវតាអង្គុយនៅគល់ជ្រៃ ខ្ញុំឃើញខ្ញុំភ័យខ្លាំងពុំស្បើយ
ទេវតាអង្គុយធ្វើព្រងើយ ម្ចាស់អើយប្រាជកឥតក្កែងកាយ ។
នាងសុជាតាស្តាប់ទាសី ត្រេកអរប្រិមប្រិយហួសនិយាយ
ទើបនាំទាសីទូលជន្លាយ បាយាសទៅថ្វាយលាបំណាន់ ។
ដល់ហើយនាងចូលដោយសន្តាត ក្រាបទាបព្រះបាទថ្វាយអភិវន្ទ
ទូលថាខ្ញុំសូមលាបំណាន់ ដែលបន់ពីមុនណាម្ចាស់ថ្លៃ ។
ព្រះអង្គទ្រង់ត្រាស់ថាអាត្មា មិនមែនទេវតាអារក្សជ្រៃ
ជាមនុស្សអ្នកបួសនៅក្នុងព្រៃ រត់ភ័យខ្លាចកើតចាស់ឈឺស្លាប់ ។
រកធម៌ត្រាស់ដឹងជាព្រះពុទ្ធ ធ្វើសង្សារវដ្តឲ្យផុតឆាប់
សំដែងទេសនាឲ្យសត្វស្តាប់ ថ្លែងប្រាប់ទោសគុណអ្នកពាល់គ្នា ។

បើនាងចង់ថ្វាយដល់អាត្មា ចូរតាំងសច្ចាដោយសទ្ធា
កុំជឿអារក្សខ្មោចអ្នកតា ជាប់ប្រាជ្ញាបានដូចចិត្ត ។
បារមីដែលនាងសាងច្រើនជាតិ ផលនោះមិនឃ្លាតខុសគំនិត
និស្ស័យមានហើយចូរមកជិត ប្រគេនជីវិតគជាគត ។
មធុបាយាសដែលនាងថ្វាយ ដោះស្រាយអំពីបំណាច់ផុត
សទ្ធាជ្រះថ្លាដោយមោះមុត ព្រះពុទ្ធទ្រង់ឆាប់បានត្រាស់ឆាប់ ។
នាងបង្គំលាកាត់សំដៅ ត្ឡោះទៅគ្រឹះឋានយ៉ាងប្រញាប់
ដើម្បីសំដែងរឿងរ៉ាវប្រាប់ ស្វាមីឲ្យឆាប់បានដឹងន័យ ។
ព្រះអង្គឆាន់ហើយកាន់ភាជន៍ទៅ ដល់ស្ទឹងទឹកជ្រៅហូរលឿនក្រៃ
ឈ្មោះនេរញ្ជរាថ្លាប្រពៃ ព្រះអង្គលើកដៃផ្សងសច្ចា ។
ថាបើបានត្រាស់គង់ថ្ងៃហ្នឹង ភាជន៍អណ្តែតរឹងច្រាសទឹកគា
បើមិនបានត្រាស់ឲ្យផលសា ៗ ញូភាជន៍សុវណ្ណាបណ្តោយទឹក ។
ព្រះអង្គដាក់ភាជន៍ទៅក្នុងស្ទឹង ភាជន៍អណ្តែតរឹងច្រុសទឹក
ឆាំង ៗ លឿនណាស់ទៅច្រាសទឹក ព្រះអង្គទ្រង់ទឹកថាត្រាស់ឆាប់ ។
ទ្រង់ស្តេចនិមន្តមកតាមផ្លូវ មានព្រាហ្មណ៍ថ្វាយស្បូវ ៨ ក្តាប់
ស្បូវនេះយកទៅទ្រង់មានគ័ព្ទ ទ្រង់គង់បានជាប់ផុសបល្ល័ង្ក ។
ព្រះអង្គទទួលស្បូវពីព្រាហ្មណ៍ ទៅក្បាមទ្រង់ឈរទ្រើងសំគាំង
ក្រោមពោធិព្រឹក្សទ្រង់ទឹកតាំង ខាងត្បូងផ្អៀងខ្ទាំងដីមិនរាប ។

យកស្បូវទៅក្រាលពីខាងលិច    ដីផ្អៀងបន្តិចមិនស្មើភាព
ទៅក្រាលខាងជើងក៏មិនរាប    ឃើញភាពមិនស្មើមិនស្អាតបាត ៗ
ទ្រង់ក្រាលពីខាងទិសបូព៌ា    ទើបទ្រង់ឃើញថាគ្មានគ្រោតគ្រាត
ផែនដីស្មើធេងស្មោផ្កាព្រាត    មានដីស្អាតទើបគង់ផ្គត់ ៗ
គឺទិសខាងកើតទ្រង់បែរមុខ    ទិស ៣ លើកទុកចោលចេញផុត
អ្នកប្រាជ្ញសំដែងថាព្រះពុទ្ធ    បានត្រាស់ចំហុតតែងបែរភក្ត្រ ៗ
ទៅបូព៌ទិសាជាទៀងទាត់    ឯព្រះមហាសត្វដ៏ឯកអគ្គ
ជាម្ចាស់នៃយើងក៏ទ្រង់ស្ម័គ្រ    បែរភក្ត្រទៅកើតហើយសច្ចា ៗ
ថាយើងអង្គុយនៅទីនេះ    ឈប់ស្ទេះលះលែងរើកាយា
ទោះបីឈាមសាច់ស្ងួតម្ដេចម្ដា    អាត្មាក៏ស៊ូលែងក្រោកឡើង ៗ
សច្ចារួចហើយបែរភក្ត្រា    ឆ្ពោះបូព៌ទិសាយ៉ាងថ្កុំថ្កើង
ស្រាប់តែបល្ល័ង្កពេជ្រផុសឡើង    ក្ដីប្រាលរុងរឿងពេញទាំងព្រៃ ៗ
ជ្រាបច្បាស់ថាអញមានរំពឹង    ទឹងបានត្រាស់ដឹងអស់ទុក្ខភ័យ
អញលែងទៅកើតភពដ៏ទៃ    ព្រោះហេតុបានញេយ្យធម៌ពិត ៗ
គិតស្រេចស្ដេចឡើងគង់បល្ល័ង្ក    ពែនភ្នែនហើយតាំងប្រឹងប្រព្រឹត្ត
ទ្រង់ដកដង្ហើមហើយទ្រង់គិត    អនាប្រាណពិតតួកម្មដ្ឋាន ៗ
ទ្រង់ស្គាល់ខ្យល់តូចនឹងខ្យល់ធំ    ចេញចូលប្រជុំពេញតែប្រាណ
ទ្រង់ធ្វើអារម្មណ៍ឲ្យសព្រាន្ត    មិនយូរប៉ុន្មានទ្រង់បានត្រាស់ ៗ

ទ្រង់តាំងបញ្ចេញពណ៌រស្មី　　ឆព្វណ្ណរង្សីភ្លឺថែនច្បាស់
ស្រាប់តែកូនមារ ៣ ល្អណាស់　　ចង់ព្រះជាម្ចាស់ដោយនិមិត្ត ៗ
រាគី រាគា អារតី　　កូនមារទាំង ៣ ចូលមកជិត
ព្រះអង្គទ្រង់ឃើញដោយនិមិត្ត　　មិនមែនរូបពិតគឺទុគ្គហៈ ៗ
រាគី គឺភ្លើងរាគៈទេ　　ជាមេកិលេសអាសវៈ
រាគាញអារម្មណ៍ទៅទម្លាក់　　ទ្រង់បានឃើញជាក់តាមដំណើរ ៗ
វិបស្សនូបក្កិលេស　　ទ្រង់ឃើញច្បាស់ថែសមិនប្រសើរ
ឃើញដូចពិម្ពាស្រស់ប្រហើរ　　មកធ្វើដំណើរការមិនសម ៗ
ឃើញដូចជាទ្រង់មិនទាន់បួស　　ចិត្តចេញទៅហួសឥដ្ឋារម្មណ៍
ឃើញដូចទ្រង់បានអភិរម្យ　　នូវរូបារម្មណ៍នាំហ្មងសៅ ៗ ៗ
បោលរូបទទេកណ្ដាលព្រៃ　　ទ្រង់ភ្ញាក់ព្រះទ័យដូចភ្លើងក្ដៅ
ជាហើយរាគីអញធ្លាប់នៅ　　ឥឡូវមកលេងអញទៀតហើយ ៗ
អនិច្ចាប្រែថាមិនទៀងទេ　　បានជាអញរេរត់គោះគើយ
បើទៀងអញនៅក្នុងរាំងហើយ　　តួជាតិនេះហើយជាភ្លើងមួយ
ជរាព្យាធិជាមេស្លាប់　　ចិត្តឯងមិនស្ដាប់ចេះតែព្រួយ
អនិច្ចធម៌លក្ខណៈមួយ　　មកជួយផ្ដន្ទារាគីចេញ ៗ
ព្រះអង្គទ្រង់តាំងបធានធំ　　ចង់ភ្លាប់អារម្មណ៍ខំបំពេញ
រាយនីវរណៈប្រានបណ្ដេញ　　ចិត្តត្រង់រលេញអរិយសច្ច ៗ

វិលចូលមកកាន់វិបស្សនា ធ្វើឈានកាប់ក្ពាក់គីផ្តាច់
ឧគ្គហនិមិត្តឃើញសម្រេច ឃើញឈឺប្រកាច់ចាស់ខ្លួនកោង ៗ
ដកដោះយាវដើរចេញទៅ សក់សតខ្មៅស្កូវសំពោង
អនិច្ចលក្ខណ៍មកជួយយោង នេះសុទ្ធតែគ្រោងវិបស្សនា ៗ
ទ្រង់ខំព្យាយាមតទៅដល់ កប់ខ្យល់បស្សាសរាគា
ស្រាប់តែកូនមារ ១ ឈ្មោះថា នាងស្រីរាគាចូលមកទៀត ៗ
ព្រោះហេតុអារម្មណ៍រនាំទៅ និមិត្តសំដៅទោសបៀតបៀន
រាគាកិលេសមកជ្រែកប្រៀត ឲ្យឈ្លៀតទឹកទៅនគរ ៗ
រាគាកិលេសរមកតាម គឺវត្ថុកាមដោយគណនា
កិលេសកាមមានទ្រព្យ របស់រាគាគ្មានវិញ្ញាណ ៗ
គឺស្បូតប៉ូត្រអលង្ការ កុណ្ឌលសង្វារទាំងប៉ុន្មាន
និមិត្តឃើញទ្រង់ពាក់ថ្កើងថ្កាន នៅលើទីស្ថានទៃនបទ្ទុ ៗ
រាគារទាញអូសគំនិត រាបាំងរាបិទខ្ទប់អារម្មណ៍
ពីព្រោះចិត្តធ្លាប់ត្រាំគង់ជ្រាំ បានជារនាំកាត់សំដៅ ៗ
រាគាកិលេសប្រានគំនិត ឧគ្គហនិមិត្តឃើញក្រឡៅ
មេនំមេនាងស្រស់ស្រដៅ រាគាមកហៅទៅក្រសាល ៗ
ស្រីស្នំក្រមុំព្រហ្មចារី មានក្មេងតន្ត្រីត្រេកត្រអាល
រាគា គឺត្តប់ចិត្តស្រើបស្រាល បណ្ដាលព្រះទ័យជិត ១ ម៉ោង ៗ

ស្រាប់តែប្រែខ្លាកចាកសប្បាយ ព្រះទ័យនឿយណាយព្រោះប្រហាន
ទ្រង់ក្តៅក្នុងចិត្តប្រិតក់យ៉ាងផ្សាង ព្រះអង្គខំណោនទុក្ខា ៗ
ទុក្ខំជាទុក្ខពិតប្រាកដ បានជាអញរត់ត្រាប់យាត្រា
ព្រោះខ្លាចទុក្ខខ្លាំងណាំចិត្តណាំ ថាឃើញគាហោរអប្រិយ ៗ
អញមកបានត្រាស់លើបល្ល័ង្ក ពគាមកបាំងអញធ្វើអ្វី
ហង់ទៅវិញចុះកាឡកណ្ណី អញមិនធ្វើប្តីហង់ទៀតទេ ៗ
ព្រះអង្គក៏ខំប្រឹងបរិកម្ម ក្លាប់បង់អារម្មណ៍មិនឲ្យរេ
ឃើញតែទុក្ខំឥតសុខទេ លុះតែនិមិត្តឃើញរាគា ៗ
ឃើញដូចពួកល្ខោននឹងស្រីស្នំ កំពុងតែរាំបាស់ដរា
ធ្មេញបាក់ខ្នងគោងទ្រមគ្រាំគ្រា គ្រប់រូបពល់គ្នាមិនគួរត្រេក ៗ
កូនមារមួយទៀតឈ្មោះអារតី គំរប់ជាបីគ្រឿងដម្រេក
និមិត្តឃើញទ្រង់កំពុងត្រេក សប្បាយជ្រុលពេកញ័រត្រឡើយ ៗ
អកុសលធម៌ដ៏អាក្រក់ តែងតាមមកចក់រកកពបី
នេះឯងជាតួអារតី និមិត្តទាំងបីកូនមារា ៗ
អញស្គាល់ក្បាលហើយមេចង្រៃ អញយកព្រះត្រៃលក្ខណា
អនិច្ចំ ទុក្ខំ អនត្តា ធម៌បីនេះណាផ្ចាញ់មេបី ៗ
ជាធម៌អាក្រក់ខ្លាំងមហិមា រាគី រាគា អារតី
វិនាសសាបសូន្យគ្មានសល់អ្វី ដែលព្រះជិនស្រីយកបញ្ញា ៗ

គឺឃើញដោយញាណឈានចំពោះ ធម៌ទន្តីនោះដ៏ថ្លៃថ្លា
មិនមែនកូនមារមកពីណា គឺទ្រង់កាប់ផ្កាតណ្ហាក្រៃ ។
គឺចិត្តហើយនឹងចេតសិក ប្រាជ្ញលោកឧបត្តកជាឧបមេយ្យ
ធម៌អភិធម្មជ្រាលជ្រៅក្រៃ កៃវៃនិទានឲ្យស្រួលស្ដាប់ ។
នេះក្រុមធម៌ក្រធ្វើកើតណាស់ បើយើងចង់ច្បាស់ត្រូវមើលច្បាប់
សន្សំបារមីព្យាយាមគ្រាប់ ត្រូវខំរៀនធាប់កុំប្រហែស ។
រៀនសូត្រឲ្យចាំចេះមុតមាំ ដឹកនាំចិត្តយើងមិនឲ្យធ្វេស
ឲ្យបានជាមនុស្សល្អវិសេស ឃ្លាតចាកកិលេសផុតអបាយ ។

## មារវិជយបរិច្ឆេទ

### បទព្រហ្មគីត

កាលព្រះសាស្ដាចារ្យ ផ្ចាញ់កូនមារចាញ់អន្តរាយ
វិនាសប្រាសខ្ចាត់ខ្ចាយ ខ្ចាតទៅឆ្ងាយដោយញាណញេយ្យ ។
ស្រាប់តែមារលើកពល ចូលមកដល់ជាច្រើនក្រៃ
រសៀលពេលល្ងាចថ្ងៃ ជិះដំរីមេខលា ។
ព្រះអង្គឃើញដោយឈាន គឺកម្មដ្ឋានវិបស្សនា
និមិត្តពីរមាត្រា បដិភាគ ឧគ្គហៈ ។
លោភៈជាដំរី មារអប្រិយគឺទោសៈ
ចិត្តខឹងជាតួយក្ស មកសត្រូវនឹងឈាន ៤ ។

មោហៈគឺមាក　　មកពាធាបិត ៩
បែកដៃប្រើនខ្លួនស្ដាំ　　គឺកោធៈវីនទីនពេក ។
ពោយខ្ជិលពោយបង្កេះ　　ណែនស៊ើរប្រេះក្នុងកាយលោក
ស្ពឹកជើងបែកញើសជោក　　ដាលកញ្ជ្រោកក្នុងព្រះអង្គ ។
ធ្វើឈានបហានៈ　　ធម៌គបៈទាញតម្រង់
ធ្វើចិត្តឲ្យស្ងប់ត្រង់　　កងពលមារជាង ១.០០០ ។
៩០០ កិលេសសុទ្ធ　　ព្រះសម្ពុទ្ធបាប់ជិះជាន់
ព្រះអង្គទ្រង់គិតទាន់　　រួមតណ្ហា ១០៨ ។
ព្រមទាំងឧបាទាន　　ទ្រង់កាយប្រានដោយបារមី
អកុសលព្រះជិនស្រី　　កាយបណ្ដាញអស់តែម្ដង ។
អកុសលធម៌លាមក　　កាមកច្ឆក់រកបំណង
ព្រះអង្គបាប់មកក្រង　　ធម៌ជាកងដាក់ដោយខ្លួន ។
អរិយសច្ចព្រហ្មវិហារ　　បែកប្រការមាន ៤ ។
អាសវៈអន្លង់ ៤　　កាជ្រមុចអរិយសច្ច ។
អគតិ ៤ នោះកា　　រួមសមគ្គាឧយៈកាប់
ទាញព្រហ្មវិហារដាច់　　ទម្លាក់ទៅអបាយ ៤ ។
៤ ។ គ្រប់ ៣ ជង　　១២ ជងឲ្យខ្ជាប់ខ្ជួន
អរិយសច្ច ៤　　ព្រហ្មវិហារជា ៨ ។

ចិត្តល្អមានតិចទេ　　អាក្រក់តែដេរដាសដី
រួមធម៌បាបពេញទី　　១៥ទៀតបង្អៀតពេញ ៗ
១០ ៥ ទឹកកាមគុណ　　គេកើតមុនមិនព្រមចេញ
នីវរណៈ ៥ ព្រួតវេញ　　វាយបណ្ដេញបីតិ ៥ ៗ
មិនឈ្នះគូអង្គឈាន　　ទ្រង់ក្លាហានប្រឹងបរិកម្ម
ស្រាប់តែវាទៅនាំ　　ធម៌ ៦ ចូលមកទៀត ៗ
កិលេសនិងតណ្ហា　　៣ ដូចគ្នាមកបៀនបៀត
៦ ក្រុមមកទៀត　　មកបំផ្លាញត្រៃលក្ខណ៍បី ៗ
ព្រះអង្គទ្រង់ខំប្រាំង　　ដោយសប្តុំទីងខន្តី
លើកយកធម៌តាំងបី　　សីល សមាធិ បញ្ញា ៗ
ទ្រង់គង់លើបល្ល័ង្ក　　ទ្រង់ខំតាំងអានាបា ...
ឃើញមារមកតវ៉ា　　យកបល្ល័ង្ករបព្រះពុទ្ធ ៗ
កន្ទ្វែងមារធ្លាប់នៅ　　ពេលមារទៅមារតយុទ្ធ
កិលេសវាខ្លាចផុត　　ស្ដាយរូបកាយរបស់វា ៗ
វាសួរថាសិទ្ធត្ថ　　ដេញកំចាត់យើងទៅណា
ព្រះអង្គយកហត្ថា　　ចុចផែនដីជាកសិណ ៗ
មារនៅក្នុងដីហ្នឹង　　បើងឹងរសសំឡេងក្អិន
ឃើញរូបដីមិនដឹង　　ដីត្រូវការសេតនូវកាម ៗ

បើជីបេះទឹងអរ បូរអ្នកបរាំយប្រាប់ប្រាម
បើជីសើបយំតាម មារឯងនៅក្នុងជីពៅ ៗ
ចំណែកកតជាគត បានរំលត់គ្មានសល់នៅ
រូបរសក៏មិនត្រូវ ក្លិនសម្ផស្សសំឡេងឡើយ ៗ
សព្វំទឹងទុក្ខ ជាបារមីបានដល់ត្រើយ
ព្រះអង្គទ្រង់កន្តើយ ទ្រង់ព្រះនាមអរហំ ៗ
ឆ្ងាយចាកសឹកសត្រូវ កិលេសពៅលែងជាខ្មាំង
គួរម៌អរហំ ផុសកណ្ដាលព្រះគុក ៗ
គឺចតុណ្ណរង្សី ដូចស្ត្រីស្រស់សពុំង៉ា
បូកណាឲ្យឈ្មោះថា នាងគង្ហីងព្រះធរណី ៗ
ប្បូតសក់ឲ្យចេញទឹក ជន់សន្ធឹកជាជលធី
សឹងមាននៅក្នុងទី បរមត្ថលោកសំដែង ៗ
គឺប្បូតទឹកព្រះទ័យ ជ្រាបញាណញៀយជ្រោយអង្គឯង
ផ្សាយចិត្តគ្រប់កន្លែង ក្នុងត្រៃលោកកើតវិជ្ជា ៗ
ប្រកាសពេញអក្ខរៈ តាមមគធៈជាភាសា
ដែលយើងរៀនរាល់គ្នា គឺអនេកជាតិនោះ ៗ
រាប់រៀបជាតិកំណើត ស្លាប់ហើយកើតគ្មានចន្លោះ
សត្វជីសត្វកៀនកោះ ទឹកប់ខ្មោចរៀនរាល់ខ្លួន ៗ

| | |
|---|---|
| ទឹកលិចពិតចំហុត | សីលបរិសុទ្ធយាន៍មាំមួន |
| ទឹកសីលហូរសំទួន | លិចពលមារកិលេស ។ |
| ក្រពើត្មាមមករ | ផ្អើលឈូរឆេរកុំប្រហែស |
| បីតិកើតក្ដីបេស | គឺសោតាសកទា ។ |
| អនាគាមគ្គផល | ផេញតាមដល់អភិញ្ញា |
| អរហត្តដេញទល់គ្នា | គឺមគ្គផលស៊ីកិលេស ។ |
| មិនមែនត្មាមតរប្លាន | ត្មាមកម្មដ្ឋានជាពិសេស |
| ប្អូនអ្នកកុំប្រហែស | ខំផ្ចាញ់មាររបស់ខ្លួន ។ |
| កុំផ្ចាញ់មារឲ្យព្រះ | ដែលទ្រង់ឈ្នះហើយមាំមួន |
| មារកន្ទ្របខ្លួន | ម្ដេចអាចារ្យមិនខំផ្ចាញ់ ។ |
| ត្រូវមើលច្បាប់ឲ្យល្អ | ព្រះពុទ្ធឈ្នះចិត្តកំណាញ់ |
| ឈ្នះស្អប់ឈ្នះស្រឡាញ់ | ឈ្នះសប្បាយលែងមានភ័យ ។ |
| ខ្ញុំ ឈ្មោះបណ្ឌិតប៊ុន | លើកធម៌កន្ធដ៏ប្រពៃ |
| ពន្យល់គ្រាន់ជាន័យ | ជនប្រុសស្រីគួរតែរៀន ។ |
| ខ្ញុំលើកជាពាក្យកាព្យ | ត្រង់តាមភាពមិនបៀតបៀន |
| ធម៌នេះទុកប្រឹតប្រៀន | ខ្លួនឲ្យបានដូចព្រះពុទ្ធ ។ |
| ដល់ព្រះស្រីអារ្យម្ចាស់ | ទ្រង់បានត្រាស់ច្បាស់ប្រាកដ |
| ឲ្យខ្ញុំបានរំលត់ | បានសម្រេចជាសាវ័ក ។ |

សូមទាទ់ព្រះពុទ្ធម្ចាស់ ទើបបានត្រាស់អស់រាគៈ
សូមក្ស័យអាសវៈ ផុតអន្ទង់ទាំង ៤ នោះ ។
រៀបរាប់មកប៉ុណ្ណោះ លោកអ្នកបេះសូមសង្គ្រោះ
បើមិនត្រូវចំពោះ សូមអភ័យទោសខ្ញុំផង ។
អក្ខរៈពាក្យបាលី ឬសំដីបើទាស់ឆ្គង
លើសខ្វះផ្ដោះរំលង ក៏អភ័យទោសផងណា៎ ។
ថ្លែងរឿងពុទ្ធប្រវត្តិ សូមសន្ទតនិដ្ឋា
សូមផលដែល៖ស្វាហ៍ ជាបច្ច័យនិព្វានហោង ។

អវសាន

រោងពុម្ព ពាភ លេខ ០១១៦
មហាវិថី ព្រះបាទនរោត្តម